ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១៧០/១៦ - ចាយូ (ខេមបូឌា) អឹមតែរីល មេនូហ្វេកឆឺរីង ខូអិលធីឌី

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **សេង រ៉ូចហ៊ិន**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ចាយូ (ខេមបូឌា) អឹមតែរីល មេនូហ្វេកឆឺរីង ខូអិលធីឌី**

អាសយដ្ឋាន ៖ ភូមិសំបួរ សង្កាត់ច្បាមន ក្រុងច្បាមន ខេត្តកំពង់ស្ពឺ

ទូរស័ព្ទ ៖ ០១០ ៧៥៨ ៥៨៩ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

លោក មួង ផានី រដ្ឋបាល

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ - **សម្ព័ន្ធសហជីពកម្ពុជា**

- **សហជីពកម្ពុជាប្រចាំក្រុមហ៊ុន ចាយូ (ខេមបូឌា) អឹមតែរីល មេនូហ្វេកឆឺរីង ខូអិលធីឌី**

អាសយដ្ឋាន ៖ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៦៦៧ ០៥៨ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

១- លោកស្រី សារី បុត្រចរិយា មេធាវី

២- លោក ឈេន សំបូរ ជំនួយការមេធាវី

| | |
|---|---|
| ៣- លោក សល់ គឹមសាន | មន្ត្រីសហព័ន្ធសហជីពកម្ពុជា |
| ៤- លោក ឡេង សេងហុង | មន្ត្រីសហព័ន្ធសហជីពកម្ពុជា |
| ៥- លោក ម៉ៃ សាមិត្ត | គណៈកម្មការសហព័ន្ធសហជីពកម្ពុជា |
| ៦- អ្នកស្រី សៀក សារ៉េត | ប្រធានសហជីពកម្ពុជាប្រចាំក្រុមហ៊ុន ចាយូ (ខេមបូឌា) អីភែរីល មេនូហ្វេកឆឺរីង ខូអិលធីឌី |
| ៧- អ្នកស្រី គឹម លន់ | លេខាសហជីពកម្ពុជាប្រចាំក្រុមហ៊ុន ចាយូ (ខេមបូឌា) អីភែរីល មេនូហ្វេកឆឺរីង ខូអិលធីឌី |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ស្នើឱ្យក្រុមហ៊ុនទទួលយកឈ្មោះ គឹម លន់ ឱ្យចូលធ្វើការងារវិញដោយគ្មានលក្ខខណ្ឌ ។

២- ស្នើឱ្យក្រុមហ៊ុនមិនត្រូវបង្ខិតបង្ខំកម្មករ កម្មការិនីថែមម៉ោងដល់ម៉ោង ៨ យប់ ឡើយ ។

៣- ស្នើសុំឱ្យក្រុមហ៊ុនមិនត្រូវបញ្ឈប់កម្មករដោយគ្មានមូលហេតុ ។

៤- ស្នើសុំក្រុមហ៊ុននៅពេលកម្មករឈប់អត់ច្បាប់១ថ្ងៃ ២ថ្ងៃ សុំកុំបញ្ឈប់ពួកគាត់ ។

៥- ស្នើសុំឱ្យក្រុមហ៊ុននៅពេលកម្មករឈប់អត់ច្បាប់១ថ្ងៃ កុំកាត់លុយគាត់គុណនឹងពីរ ។

៦- ស្នើសុំក្រុមហ៊ុននៅពេលកម្មករមានសំបុត្រពេទ្យត្រឹមត្រូវកុំកាត់លុយពីពួកគាត់ ។

៧- នៅពេលកម្មករមានគ្រោះថ្នាក់ការងារក្រុមហ៊ុនត្រូវទទួលខុសត្រូវ និងស្នើឱ្យមានពេទ្យនៅក្នុងរោងចក្រពេលកម្មករធ្វើការ និងស្នើឱ្យមានថ្នាំពេទ្យគ្រប់គ្រាន់ ។

បន្ទាប់ពីបានទទួលពាក្យបណ្ដឹងខាងលើ មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ បានធ្វើលិខិតអញ្ជើញគូរភាគីទាំងពីរ មកសាកសួរព័ត៌មាន និងធ្វើការសម្របសម្រួលដើម្បីធ្វើការផ្សះផ្សានៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោង ៨៖០០ ព្រឹក នៅមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ ។ ជាលទ្ធផលមិនទទួលបានសះជានិងគ្នាទេ ហើយភាគីក្រុមហ៊ុនបានស្នើសុំលើកថ្ងៃផ្សះផ្សាទៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ម្ដងទៀត ក្នុងអំឡុងពេលរងចាំការផ្សះផ្សា នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ភាគីខាងសម្ព័ន្ធសហជីពកម្ពុជាបានដាក់ពាក្យបណ្ដឹងបន្ថែម ០៣ ចំណុចទៀត ។

១- ស្នើឱ្យក្រុមហ៊ុនទទួលយកឈ្មោះ សៀក សារ៉េត ចូលធ្វើការវិញ ដោយគ្មានលក្ខខណ្ឌ ។

២- ស្នើឱ្យក្រុមហ៊ុនត្រូវផ្ដល់ប្រាក់រំលឹកជូនគាត់ចាប់ពីថ្ងៃបញ្ឈប់ រហូតដល់ថ្ងៃធ្វើការងារវិញ ។

៣- ស្នើសុំក្រុមហ៊ុនមិនត្រូវការគំរាមកំហែងចំពោះថ្នាក់ដឹកនាំសហជីព បញ្ឈប់ការរើសអើងសហជីព និងមិនត្រូវបង្ខិតបង្ខំឱ្យលាលែងពីការងារឡើយ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២២២ កប/ប្រក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ (អាណត្តិទី១៤)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ចាយូ (ខេមបូឌា) អឹមភែរីល មេនូហ្វេកឆឺរីង ខូអិលធីឌី លេខ ២៣១៧/១៦ កប/កស្ក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦។

### សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៦ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក )។

បញ្ហានីតិវិធី ៖

នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ បានទទួលពាក្យបណ្តឹងរបស់សម្ព័ន្ធសហជីពកម្ពុជា ទាមទារលក្ខខណ្ឌការងាររួមចំនួន ០៧ ចំណុច។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាវិវាទចំនួន ០៧ ចំណុច នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ ដោយមូលហេតុថានិយោជកបានសុំលើកថ្ងៃផ្សះផ្សាទៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ វិញ ហើយសម្ព័ន្ធសហជីពកម្ពុជាបានដាក់ពាក្យបណ្តឹងបន្ថែមចំនួន ០៣ ចំណុចទៀត។ នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ភាគីនិយោជកបានសុំលើកថ្ងៃផ្សះផ្សាទៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦ម្តងទៀត ប៉ុន្តែ នៅថ្ងៃផ្សះផ្សាភាគីនិយោជកនៅតែមិនបានមកចូលរួមផ្សះផ្សា។ ហេតុនេះ ចំណុចមិនសះជាចំនួន ១០ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ចាយូ ខេមបូឌា អឹមភីរីល លេខ ២៣១៧/១៦ កប/កស្ក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាទាំង ១០ ចំណុច ចំនួន ០២ លើក ដោយលើកទី០១

THE ARBITRATION COUNCIL

ធ្វើឡើងនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោង ១៤ និង ០០ នាទី រសៀល និងលើកទី០២ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទដែលនៅសល់ទាំងនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ១០ ចំណុចនេះបន្ថែមទៀត ដោយភាគីទាំងពីរបានព្រមព្រៀងគ្នាលើចំណុចវិវាទចំនួន ០៧ ចំណុច គឺចំណុចវិវាទទី០២ ដល់ទី០៧ និងចំណុចវិវាទទី០៣ (ក្នុងចំណុចបន្ថែម នៅពេលផ្សះផ្សាថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦)។ ទន្ទឹមគ្នានោះដែរ ភាគីកម្មករនិយោជិតបានសម្រេចបញ្ចូលចំណុចវិវាទទី០១ និងទី០២ ដែលជាបន្ថែមនៅពេលផ្សះផ្សាថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ជាមួយគ្នា។ ដូចនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាតែចំណុចវិវាទ ដែលនៅសល់ចំនួន ០៣ គឺចំណុចវិវាទទី០១, និងចំណុចវិវាទទី០១ និងទី០២ (ក្នុងចំណុចបន្ថែមនៅពេលផ្សះផ្សាថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦)។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៦ ទៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦ របស់នាយកក្រុមហ៊ុន ចាយូ (ខេមបូឌា) អ៊ីភៃរីល មេនូហ្វេកឆឺរីង ខូអិលធីឌី ផ្ទេរសិទ្ធិជូន លោក មួង ផានី។

២- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ចាយូ (ខេមបូឌា) អ៊ីភៃរីល បានឃើញ និងបញ្ជាក់ថា ត្រឹមត្រូវដោយប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ លេខ ១០៩៤/១៤ ក្រសួ ចុះថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ២០១៤។

៣- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ក្រុមហ៊ុន ចាយូ (ខេមបូឌា) អ៊ីមភីរីល ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦។

៤- លិខិតលេខ ២២៧១/១៦ កប/កស្ត ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ របស់ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ ជម្រាបមក លោក-លោកស្រីនាយកក្រុមហ៊ុន ចាយូ ខេមបូឌា អ៊ីមភីរីល ស្តីពីសូមអញ្ជើញលោក-លោកស្រី ចូលរួមប្រជុំនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

៥- លិខិតលេខ ០៦៦/១៦ សសក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦ របស់សម្ព័ន្ធសហជីពកម្ពុជា គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ ស្តីពីសំណើសុំអន្តរាគមន៍ ករណីរោងចក្រ កាត់ដេរ ចាយូ ខេមបូឌា អ៊ីមភីរីល។

៦- បញ្ជីវត្តមាន កិច្ចប្រជុំស្តីពីដោះស្រាយវិវាទការងាររួម នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦។

៧- លិខិតសុំលាឈប់ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ របស់ឈ្មោះ គីម លន់។

៨- លិខិតសុំលាឈប់ ប័ណ្ណបើកប្រាក់បំណាច់ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ របស់ឈ្មោះ សៀក សារ៉េត។

៩- ពាក្យសុំចូលបំរើការងារ និងសៀវភៅគ្រួសារ របស់ឈ្មោះ សៀក សារ៉េត។

១០- កិច្ចសន្យាការងារ រវាងក្រុមហ៊ុន ចាយូ (ខេមបូឌា) ជាមួយនឹងប្រធានក្រុម (ឈ្មោះ សៀក សារ៉េត) ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦។

១១- លិខិតព្រមានរបស់ក្រុមហ៊ុន ចាយូ ព្រមានឈ្មោះ សៀក សារ៉េត។

១២- លិខិតបញ្ជាក់ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ របស់ក្រុមហ៊ុន ចាយូ (ខេមបូឌា) អ៊ីមភីរីល។

១៣- សេចក្តីប្រកាសជូនដំណឹងស្តីពីការបើកសហគ្រាស ក្រុមហ៊ុន ចាយូ (ខេមបូឌា) អ៊ីមភៃរីល ចុះបញ្ជិកាលេខ ១០៩៤/១២ កបកស្ត ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ ដោយប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ។

១៤- លិខិតអនុញ្ញាតប្រកបអាជីវកម្ម-សេវាកម្ម-ពាណិជ្ជកម្ម សិប្បកម្មកាត់ដេរសំលៀកបំពាក់ ចាយូ (ខេមបូឌា) អ៊ីមភៃរីល លេខ ២២៦/០១៦ កចម.ប្រ.១ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦។

១៥- លិខិតជំទាស់ក្រុមហ៊ុន ចាយូ (ខេមបូឌា) អ៊ីមភៃរីល ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ គោរពជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសូមជំទាស់ទៅលើលិខិតជូនដំណឹងស្តីពីបញ្ជីរាយនាមគណៈកម្មការប្រតិបត្តិកម្ពុជា។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត៖

១- លិខិតលេខ ០៦៨/១៦ សសក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់សម្ព័ន្ធសហជីពកម្ពុជា គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ ស្តីពីសំណើសុំអន្តរាគមន៍ករណីរោងចក្រកាត់ដេរ ចាយូ ខេមបូឌា អ៊ីមភីរីល។

THE ARBITRATION COUNCIL

២- លិខិតអន្តរាគមន៍ និងផ្ទេរសិទ្ធិ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦ របស់ឈ្មោះ សៀក សាវ៉េត គោរពជូន លោកស្រី យ៉ាង សុភ័ណ្ឌ ប្រធានសម្ព័ន្ធសហជីពកម្ពុជា ស្តីពីសុំជួយអន្តរាគមន៍ទៅលើរោងចក្រ ចាយូ ខេមបូឌា អ៊ីមភឺរីល ។

៣- លិខិតលេខ ០៥៧/១៦ សសក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ របស់សម្ព័ន្ធសហជីពកម្ពុជា គោរពជូន លោកនាយករោងចក្រកាត់ដេរ ចាយូ (ខេមបូឌា) អ៊ីមភឺរីល ស្តីពីជូនដំណឹងអំពីថ្នាក់ដឹកនាំអាណត្តិទី១ សហជីពកម្ពុជា ចំនួន ០៣ រូប ។

៤- បញ្ជីឆាប់រហ័សEMS អ្នកផ្ញើ សម្ព័ន្ធសហជីពកម្ពុជា ។

៥- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ក្រុមហ៊ុន ចាយូ ខេមបូឌា អ៊ីមភឺរីល ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ ។

៦- លិខិតលេខ ០៦៦/១៦ សសក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦ របស់សម្ព័ន្ធសហជីពកម្ពុជា គោរពជូន លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ ស្តីពីសំណើសុំអន្តរាគមន៍ករណីរោងចក្រកាត់ដេរ ចាយូ ខេមបូឌា អ៊ីមភឺរីល ។

៧- បញ្ជីរាយនាមគណៈកម្មការប្រតិបត្តិសហជីពកម្ពុជានៃរោងចក្រកាត់ដេរ ចាយូ (ខេមបូឌា) អ៊ីមភែរីល មេនូហ្វេកឆឺរី ខូអិលធីឌី ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៦ របស់សហជីពកម្ពុជាប្រចាំរោងចក្រកាត់ដេរ ចាយូ (ខេមបូឌា) អ៊ីមភែរីល មេនូហ្វេកឆឺរី ខូអិលធីឌី ។

៨- កំណត់ហេតុស្តីពីការបង្កើតសហជីពកម្ពុជាប្រចាំរោងចក្រកាត់ដេរ ចាយូ (ខេមបូឌា) អ៊ីមភែរីល មេនូហ្វេកឆឺរី ខូអិលធីឌី ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៦ របស់សហជីពកម្ពុជាប្រចាំរោងចក្រកាត់ដេរ ចាយូ (ខេមបូឌា) អ៊ីមភែរីល មេនូហ្វេកឆឺរី ខូអិលធីឌី ។

៩- លិខិតចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ របស់សម្ព័ន្ធសហជីពកម្ពុជា គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសូមជំទាស់ទៅលើឯកសាររបស់ក្រុមហ៊ុន ចាយូ (ខេមបូឌា)អ៊ីមភែរីល ។

១០- កិច្ចព្រមព្រៀងរវាងភាគី និយោជក ជាមួយនឹងសម្ព័ន្ធសហជីពកម្ពុជា ក្នុងការដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន ចាយូ (ខេមបូឌា) អ៊ីភែរីល មេនូហ្វេកឆឺរីង សំណុំរឿងលេខ ១៧០/១៦ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ ។

១១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦ របស់នាយកក្រុមហ៊ុន ចាយូ (ខេមបូឌា) អ៊ីភែរីល មេនូហ្វេកឆឺរីង ខូអិលធីឌី ផ្ទេរសិទ្ធិជូន លោក មួង ផានី ។

១២- លិខិតចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ ក្រុមហ៊ុន ចាយូ (ខេមបូឌា) អ៊ីមភែរីល គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសូមជំទាស់ទៅលើលិខិតជូនដំណឹងស្តីពីបញ្ជីរាយនាមគណៈកម្មការប្រតិបត្តិសហជីពកម្ពុជា ។

ARBITRATION COUNCIL

១៣- លិខិតលាលែងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២១០៦ របស់កម្មករ-កម្មការនីដែលកំពុងបំរើការនៅរោងចក្រ ចាយូ (ខេមបូឌា) អឹមភើរីល។

១៤- បញ្ជីរាយនាមគណៈកម្មការប្រតិបត្តិសហជីពកម្ពុជា នៃរោងចក្រកាត់ដេរ ចាយូ (ខេមបូឌា) អឹមភើរីល មេនូហ្វេកឆឺរី ខូអិលធីឌី ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៦ របស់សហជីពកម្ពុជាប្រចាំរោងចក្រកាត់ដេ ចាយូ (ខេមបូឌា) អឹមភើរីល មេនូហ្វេកឆឺរី ខូអិលធីឌី។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ចាយូ (ខេមបូឌា) អឹមភើរីល មេនូហ្វេកឆឺរី ខូអិលធីឌី លេខ ២៣១៧/១៦ កប/កស្ក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ចាយូ (ខេមបូឌា) អឹមភើរីល មេនូហ្វេកឆឺរី ខូអិលធីឌី ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៨៨០ កប/អក/វក/លកអ. ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១៦។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៨៨១ កប/អក/វក/លកអ. ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ចាយូ (ខេមបូឌា) អឹមភីរីល (តទៅនេះឱ្យហៅថា "ក្រុមហ៊ុន ចាយូ") គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងក្នុងការកាត់ដេរសំលៀកបំពាក់។ បច្ចុប្បន្នក្រុមហ៊ុននេះ ជួលកម្មករនិយោជិតចំនួនប្រហែលជា ២៨០ នាក់ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ចាយូ ខេមបូឌា អឹមភីរីល)*។
- សម្ព័ន្ធសហជីពកម្ពុជា បានរៀបចំបោះឆ្នោតបង្កើតសហជីពកម្ពុជា ប្រចាំក្រុមហ៊ុន ចាយូ នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៦ ក៏ប៉ុន្តែ សហជីពនេះមិនទាន់រៀបចំដាក់ពាក្យចុះបញ្ជិកាសហជីព នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅឡើយទេ។
- សម្ព័ន្ធសហជីពកម្ពុជា បានទទួលការផ្ទេរសិទ្ធិពីកម្មករនិយោជិតរបស់ក្រុមហ៊ុន ចាយូ ចំនួន ២៨នាក់ ក្នុងការដោះស្រាយវិវាទ តាមរយៈលិខិតអន្តរាគមន៍ និងផ្ទេរសិទ្ធិ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៦។

- កម្មករនិយោជិតចំនួន ០២ នាក់ រួមមាន កម្មករនិយោជិត សៀក សារ៉េត និង គីម លន់ មានវត្តមានក្នុងសវនាការ ហើយមានឈ្មោះ និងស្នាមមេដៃក្នុងលិខិតអន្តរាគមន៍ និងផ្ទេរសិទ្ធិខាងលើ ។
- ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទក្នុងសំណុំរឿងនេះសម្រាប់កម្មករនិយោជិតចំនួន ២៨ ដែលមានឈ្មោះ និងស្នាមមេដៃក្នុងលិខិតអន្តរាគមន៍ និងផ្ទេរសិទ្ធិខាងលើ ។

**ចំណុចវិវាទទី ០១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកកម្មករនិយោជិត គីម លន់ ឱ្យចូលធ្វើការងារវិញដោយគ្មានលក្ខខណ្ឌ**

- ភាគីទាំងពីរឯកភាពថា ៖
  - ○ កម្មករនិយោជិត គីម លន់ ជាកម្មករនិយោជិតផ្នែកដេរ ហើយបានចាប់ផ្តើមចូលធ្វើការដំបូងនៅក្នុងក្រុមហ៊ុននៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ដោយមានកិច្ចសន្យាការងារសាកល្បងចំនួន ០៣ ខែ ។ កិច្ចសន្យាការងារចុងក្រោយរបស់គាត់ គឺជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ។ និយោជកបានបញ្ឈប់គាត់ពីការងារនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ។
  - ○ កម្មករនិយោជិត គីម លន់ មិនទាន់បានបើកប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារពីនិយោជកទេ ។
- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារថា ឱ្យនិយោជកទទួលយកកម្មករនិយោជិត គីម លន់ ឱ្យចូលធ្វើការងារវិញ ។
- ភាគីកម្មករនិយោជិតបានលើកឡើងពីមូលហេតុនៃការទាមទារថា និយោជកបានបញ្ឈប់គាត់ដោយមិនមានមូលហេតុច្បាស់លាស់ត្រឹមត្រូវ ហើយការបញ្ឈប់នេះ គឺដោយមូលហេតុនៃការរើសអើងសហជីព ។
- ភាគីនិយោជកបានបញ្ជាក់ថា និយោជកមិនទទួលយកកម្មករនិយោជិតរូបនេះចូលធ្វើការវិញទេ ហើយនិយោជកបានបញ្ឈប់កម្មករនិយោជិត គីម លន់ ដោយហេតុថា កម្មករនិយោជិតរូបនេះ មកធ្វើការមិនទៀងទាត់ ឧស្សាហ៍មកធ្វើការយឺត ចេញពីធ្វើការមុនម៉ោង មិនសូវស្តាប់ប្រធានក្រុម តែងតែនិយាយទូរស័ព្ទស្តាប់កាសក្នុងម៉ោងការងារ និងលេងសើចច្រើនក្នុងម៉ោងការងារ ។
- ភាគីនិយោជកបានលើកឡើងទៀតថា ៖
  - ○ និយោជកធ្លាប់ហៅកម្មករនិយោជិត គីម លន់ មកណែនាំដោយផ្ទាល់មាត់ជាច្រើនដងមកហើយ ប៉ុន្តែ កម្មករនិយោជិតរូបនេះនៅតែមិនស្តាប់ និងសហការជាមួយក្រុមហ៊ុន ។ រដ្ឋបាលបានទុកឱកាសឱ្យគាត់ច្រើនដងមកហើយ ។
  - ○ កំហុសចុងក្រោយ ដែលនិយោជកសម្រេចបញ្ឈប់គាត់ គឺនៅពេលដែលក្រុមហ៊ុនកំពុងមមាញឹកវ៉ាន់ ប៉ុន្តែ កម្មករនិយោជិត គីម លន់ បែរជានិយាយទូរស័ព្ទទៅវិញ ។ ប្រធានផ្នែករបស់គាត់ឃើញនៅពេលដែលគាត់កំពុងនិយាយទូរស័ព្ទ នឹងបានស្នើឱ្យរដ្ឋបាលបញ្ឈប់គាត់ពីការងារ ។
  - ○ និយោជកយល់ឃើញថា កំហុសទាំងនេះមិនអាចឱ្យនិយោជកបញ្ឈប់គាត់ពីការងារបានទេ ប៉ុន្តែ កម្មករនិយោជិតនេះមិនស្តាប់ការណែនាំ ហេតុនេះនិយោជកសម្រេចបញ្ឈប់គាត់ដោយផ្តល់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារចំនួន ០៥ ចំណុច ដូចជាប្រាក់ឈ្នួលចុងក្រោយ ប្រាក់បំណាច់បណ្តេញ

ចេញ សោហ៊ុយជម្ងឺចិត្ត ប្រាក់បំណាច់ទូទាត់ជួសការជូនដំណឹងមុន និងប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ។

- ភាគីកម្មករនិយោជិតបានលើកឡើងថា កម្មករនិយោជិត គីម លន់ គឺធ្លាប់លេងសើចក្នុងម៉ោងការងារមែន ប៉ុន្តែ គាត់លេងតែនៅចុងម៉ោងទេ ហើយគ្រាន់តែនិយាយលេងមួយម៉ាត់ពីរម៉ាត់ប៉ុណ្ណោះ។ ចំពោះការមកធ្វើការយឺត គាត់ធ្លាប់ប្រហែលជាមួយខែមកយឺតម្តងតែប៉ុណ្ណោះ ហើយការមកយឺតនេះគឺបណ្តាលមកពីឡានដឹកកម្មករនិយោជិត ដែលគាត់ជិះខូច។ ចំពោះការស្តាប់កាសវិញ គាត់ស្តាប់យូរៗម្តង ហើយប្រធានក្រុម និងផ្នែកមិនដែលហៅទៅព្រមានទេ តែគ្រាន់តែណែនាំជាទូទៅដល់កម្មករនិយោជិតទាំងអស់ថាមិនឱ្យប្រើកាសស្តាប់ទូរស័ព្ទ ឬចំរៀងក្នុងម៉ោងការងារ។
- ភាគីកម្មករនិយោជិតបានលើកឡើងពីព័ត៌មានសហជីពថា ៖
  - សម្ព័ន្ធសហជីពកម្ពុជា បានរៀបចំបោះឆ្នោតបង្កើតសហជីពកម្ពុជា ប្រចាំក្រុមហ៊ុន ចាយូ នៅថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៦។ មន្ត្រីសម្ព័ន្ធសហជីពកម្ពុជាបានជូនដំណឹងពីលទ្ធផលបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពកម្ពុជានៃក្រុមហ៊ុន ចាយូ ដោយយកលិខិតជូនដំណឹងចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ នោះទៅក្រុមហ៊ុននៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ប៉ុន្តែ សន្តិសុខមិនបានទទួលយកលិខិតនោះទេ។
  - មន្ត្រីសម្ព័ន្ធសហជីពកម្ពុជាបានជូនដំណឹងអំពីលទ្ធផលបោះឆ្នោតនេះម្តងទៀតតាមរយៈប្រៃសណីយ៍ នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ ប៉ុន្តែ ប្រៃសណីយ៍បានបញ្ជូនលិខិតនោះមកវិញ ដោយបានវាយត្រាថានិយោជកបដិសេធមិនទទួលនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦។
  - ពាក់ព័ន្ធនឹងលិខិតជូនដំណឹងអំពីលទ្ធផលបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពកម្ពុជានេះ សម្ព័ន្ធសហជីពកម្ពុជាបានចម្លងជូនទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ ផងដែរ។
- ភាគីនិយោជកបានបដិសេធនឹងការលើកឡើងរបស់ភាគីកម្មករនិយោជិតថា និយោជកមិនបានទទួលលិខិតជូនដំណឹងផ្សេងៗពីសហជីពកម្ពុជា ដូចភាគីកម្មករនិយោជិតលើកឡើងទាំងនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ ២០១៦ និងការផ្ញើតាមប្រៃសណីយ៍ ហើយសន្តិសុខក៏មិនបានរាយការណ៍អំពីលិខិតទាំងនេះដែរ។
- ភាគីកម្មករនិយោជិតបានដាក់ឯកសារមកក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលក្នុងនោះរួមមាន ៖
  - លិខិតជូនដំណឹងអំពីថ្នាក់ដឹកនាំអាណត្តិទី០១ សហជីពកម្ពុជា ចុះថ្ងៃទី០៧ ខែមិថុនា ដែលបានបោះឆ្នោតនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៦ ដែលរួមមាន ៖ កម្មករនិយោជិត ស្បែក សារ៉េត ជាប់ជាប្រធាន កម្មករនិយោជិត យឹម សុខចា ជាប់ជាអនុប្រធាន និងកម្មករនិយោជិត គីម លន់ ជាប់ជាលេខាធិការិនីសហជីពកម្ពុជា។
  - ស្រោមសំបុត្រពីសម្ព័ន្ធសហជីពកម្ពុជាផ្ញើរទៅក្រុមហ៊ុន ចាយូ ខេមបូឌា ដែលមិនទាន់បើក និងបង្កាន់ដៃប្រៃសណីយ៍ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ និងមានវាយត្រាពីការបដិសេធមិនទទួល

យកនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦។ ភាគីនិយោជកមិនបានដាក់ឯកសារជំទាស់លើឯកសារនេះទេ។

**ចំណុចវិវាទទី ០១ និងទី ០២ (ក្នុងចំណុចបន្ថែមនៅពេលផ្សះផ្សាថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦) ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកកម្មករនិយោជិត សៀក សារ៉េត ឱ្យចូលធ្វើការវិញដោយគ្មានលក្ខខណ្ឌ និងត្រូវផ្តល់ប្រាក់រំលឹកជូនគាត់ចាប់ពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃធ្វើការងារវិញ**

- ភាគីទាំងពីរឯកភាពថា ៖
    - កម្មករនិយោជិត សៀក សារ៉េត ជាកម្មករនិយោជិតផ្នែកដេរ ហើយបានចាប់ផ្តើមចូលធ្វើការដំបូងនៅក្នុងក្រុមហ៊ុននៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥ ដោយមានកិច្ចសន្យាការងារសាកល្បងចំនួន ០៣ ខែ។ កិច្ចសន្យាការងារចុងក្រោយរបស់គាត់ គឺជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់។ និយោជកបានបញ្ឈប់គាត់ពីការងារនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ នៅពេលចូលធ្វើការវិញ បន្ទាប់ពីការប្រជុំផ្សះផ្សានៅមន្ទីការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ។
    - កម្មករនិយោជិត សៀក សារ៉េត មិនទាន់បានបើកប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារពីនិយោជកទេ។
- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារថា ឱ្យនិយោជកទទួលយកកម្មករនិយោជិត សៀក សារ៉េត ឱ្យចូលធ្វើការងារកន្លែងដើមវិញ និងសងរំប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗចាប់ពីថ្ងៃបញ្ឈប់ពីការងាររហូតដល់ថ្ងៃចូលធ្វើការវិញ។
- ភាគីកម្មករនិយោជិតបានលើកឡើងពីមូលហេតុនៃការទាមទារថា ការបញ្ឈប់នេះ គឺពាក់ព័ន្ធនឹងការរើសអើងសហជីព ហើយនិយោជកបញ្ឈប់កម្មករនិយោជិត សៀក សារ៉េត ដោយមិនមានមូលហេតុច្បាស់លាស់។ កម្មករនិយោជិត សៀក សារ៉េត មិនដែលបានប្រព្រឹត្តកំហុសទេ និងត្រូវបាននិយោជកព្រមានពីមុនមកទេ។
- ភាគីកម្មករនិយោជិតបានលើកឡើងថា និយោជកបានដឹងពីសមាសភាពរបស់កម្មករនិយោជិត សៀក សារ៉េត ថា ជាបេក្ខជនជាប់ជាប្រធានសហជីពកម្ពុជា នៅពេលកម្មករនិយោជិតរូបនេះបានចូលរួមផ្សះផ្សានៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ មកម្ល៉េះ ដោយហេតុថា កម្មករនិយោជិតរូបនេះបានចូលរួមផ្សះផ្សា ហើយមន្ត្រីផ្សះផ្សាក៏បានបញ្ជាក់ពីសមាសភាពគាត់ជាប្រធានសហជីពនៅពេលផ្សះផ្សានោះដែរ។
- ភាគីនិយោជកបានលើកឡើងថា និយោជកមិនទទួលយកកម្មករនិយោជិត សៀក សារ៉េត ចូលធ្វើការវិញទេ ហើយនិយោជកបញ្ឈប់កម្មករនិយោជិតរូបនេះ ដោយមូលហេតុថា គាត់ធ្វើការងារមិនល្អ និងមានសមត្ថភាពខ្សោយ ព្រោះគាត់ជាប្រធានក្រុម ប៉ុន្តែ ដឹកនាំកូនក្រុមមិនបានល្អ ដោយឱ្យកូនក្រុមឈប់លើសច្រើនក្នុងម៉ោងការងារ កូនក្រុមដេរមិនគ្រប់ចំនួនកំណត់។ កម្មករនិយោជិត សៀក សារ៉េត បានប្រព្រឹត្តកំហុសដដែលៗច្រើនដងពាក់ព័ន្ធនឹងការគ្រប់គ្រងកូនក្រុមរបស់គាត់មិនបានល្អ ទោះបីជាមានការណែនាំពីប្រធានផ្នែកអំពីបញ្ហានេះក៏ដោយ ហើយធ្លាប់ឈប់សម្រាកដោយមិនសុំការអនុញ្ញាត និងមិនទទួលកំហុសដែលខ្លួនប្រព្រឹត្ត។

- ភាគីនិយោជកបានបញ្ជាក់ទៀតថា ការដែលនិយោជកសម្រេចចិត្តបញ្ឈប់គាត់ គឺដោយមូលហេតុសំខាន់ថា និយោជកខឹងកម្មករនិយោជិតរូបនេះ ដោយគាត់មិនបានយកបញ្ហាដែលមានមកដោះស្រាយនៅក្នុងក្រុមហ៊ុនជាមួយនិយោជកមុនទេ តែបែរជាយកបញ្ហានោះទៅដោះស្រាយនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺតែម្តង ។
- នៅក្នុងបញ្ជីវត្តមាន កិច្ចប្រជុំស្តីពីដោះស្រាយវិវាទរួម នៅមន្ទីរការងារបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ មានឈ្មោះ កម្មករនិយោជិត សៀក សារ៉េត ដែលបានចុះតួនាទីជាប្រធានសហជីពកម្ពុជានៅក្រុមហ៊ុន ចាយូ ។
- សូមមើលអង្គហេតុពាក់ព័ន្ធនឹងសហជីពកម្ពុជាក្នុងអង្គហេតុចំណុចវិវាទទី០១ ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

**ចំណុចវិវាទទី០១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកកម្មករនិយោជិត គីម លន់ ឱ្យចូលធ្វើការងារវិញ**

កម្មករនិយោជិត គីម លន់ បានចាប់ផ្តើមចូលធ្វើការដំបូងនៅក្នុងក្រុមហ៊ុននៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ហើយកិច្ចសន្យាការងារចុងក្រោយរបស់គាត់ គឺជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ។ និយោជកបានបញ្ឈប់គាត់ពីការងារនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ។ ភាគីកម្មករនិយោជិតលើកឡើងថា កម្មករនិយោជិត គីម លន់ ជាបេក្ខនារីជាប់ជាលេខាធិការិនីសហជីពកម្ពុជា ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា ដូចខាងក្រោម ៖

**១. តើកម្មករនិយោជិត គីម លន់ ទទួលបានការពារពិសេសពីការបញ្ឈប់ពីការងារដែរ ឬទេ?**

មាត្រា ៤៣ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ បានចែងថា "*រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាម្នាក់ពីការងាររបស់ខ្លួន អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីអធិការការងារ ។...*

*អធិការការងារ ដែលបានទទួលពាក្យបណ្តឹងសុំបញ្ឈប់កម្មករនិយោជិត ដូចមានចែងក្នុងមាត្រានេះ ត្រូវផ្តល់សេចក្តីសម្រេចរបស់ខ្លួនដល់និយោជក និងដល់កម្មករនិយោជិតដែលត្រូវបញ្ឈប់... ក្នុងរយៈពេល ១ (មួយ)ខែ យ៉ាងយូរ ក្រោយទទួលពាក្យបណ្តឹង ។*

*បន្ទាប់ពីបានទទួលសេចក្តីសម្រេចនោះ និយោជក ឬកម្មករនិយោជិត ដែលត្រូវបញ្ឈប់ ឬសហជីពរបស់កម្មករនិយោជិតនោះ មានពេល ២ (ពីរ)ខែ ដើម្បីធ្វើការតវ៉ាទៅរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ អាចលុបចោល ឬកែសម្រួលសេចក្តីសម្រេចរបស់អធិការការងារ ។*

*បើគ្មានការជូនដំណឹងអំពីសេចក្តីសម្រេចរបស់អធិការការងារ ក្នុងរយៈពេលដែលបានកំណត់ឱ្យទេ ឬបើគ្មានការជូនដំណឹងអំពីសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារក្នុងរយៈពេល ២ (ពីរ)ខែ បន្ទាប់ពីបានទទួលការតវ៉ាតាមឋានានុក្រម ពាក្យបណ្តឹង និងការតវ៉ានោះ ត្រូវចាត់ទុកថា បានបដិសេធចោល ។*" ។

សំណុំរឿងលេខ ១៨១/១៦-អ៊ូ ថុង អភិវឌ្ឍន៍កម្ពុជា ខូ អិលធីឌី ហេតុផលនៃចំណុចវិវាទទី០១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបកស្រាយថា " *រាល់ការបញ្ឈប់កម្មករនិយោជិត ដែលជាប្រតិភូបុគ្គលិក ឬកម្មករនិយោជិតណា*

*ម្នាក់ដែលត្រូវទទួលបានការការពារពីការបញ្ឈប់ស្របតាមមាត្រានេះ និយោជកត្រូវទទួលបានការអនុញ្ញាតពីអធិការការងារជាមុនសិន មុននឹងធ្វើការបញ្ឈប់ពួកគាត់ពីការងារ ។ មិនតែប៉ុណ្ណោះ ក្នុងករណីដែលនិយោជកធ្វើបណ្ដឹងតវ៉ាលើសេចក្ដីសម្រេចរបស់អធិការងារ និយោជកក៏ត្រូវទទួលបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារជាមុនសិនដែរ មុននឹងធ្វើការបញ្ឈប់ កម្មករនិយោជិតដែលទទួលបានការពារពីការបញ្ឈប់ខាងលើ ។*

មាត្រា ៤៣ នៃច្បាប់ស្ដីពីសហជីពខាងលើនេះ ក៏ត្រូវបានអនុវត្តចំពោះកម្មករនិយោជិត ដូចមានចែងក្នុងមាត្រា ៦៧ នៃច្បាប់ស្ដីពីសហជីពដដែលនេះ ដែលចែងថា ៖ *"កម្មករ និយោជិតទាំងអស់ដែលជាបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំគ្រប់គ្រងសហជីព ទទួលបាននូវការការពារពីការរងគ្រោះ និងការបញ្ឈប់ពីការងារដូចប្រតិភូបុគ្គលិកដែរ ។ ការការពារនេះមានរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ មុនការបោះឆ្នោត ហើយត្រូវបញ្ចប់ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ ក្រោយការបោះឆ្នោត ប្រសិនបើបេក្ខជនទាំងនេះមិនបានជាប់ឆ្នោត ។ ដើម្បីទទួលបានការការពារពិសេសនេះ សហជីពត្រូវជូនដំណឹងទៅនិយោជក និងចម្លងជូនក្រសួងទទួលបន្ទុកវិស័យការងារអំពីបេក្ខភាពនេះ តាមគ្រប់មធ្យោបាយទាំងអស់ដែលទុកជាបានការ ។ និយោជកត្រូវអនុវត្តបទប្បញ្ញត្តិនេះតែម្ដងគត់ នៅរៀងរាល់ពេលបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ។"*

យោងតាមសំណុំរឿងលេខ ១៦៩/១៦-ម៉នីង គ្លរី ហ្គាមេន អ៊ីនធើប្រាយ ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី០១ ក្រុមប្រឹក្សាងអាជ្ញាកណ្ដាលបានបកស្រាយថា " *យោងតាមមាត្រា ៦៧ នៃច្បាប់ស្ដីពីសហជីព ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ដើម្បីទទួលបានការការពារពិសេសពីការបញ្ឈប់ពីការងារ កម្មករនិយោជិតត្រូវបំពេញលក្ខខណ្ឌ ចំនួន ០៣ គឺ លក្ខខណ្ឌទី១ ៖ កម្មករនិយោជិត គឺជាកម្មករនិយោជិតដែលទទួលបាននូវការការពារពិសេស, លក្ខខណ្ឌទី២ ៖ ការបញ្ឈប់ពីការងារស្ថិតនៅ ក្នុងពេលដែលពួកគេ បានទទួលនូវការការពារ (រយៈពេល ៤៥ ថ្ងៃ មុនថ្ងៃបោះឆ្នោតសហជីព និងត្រូវបញ្ចប់ក្នុង រយៈពេល ៤៥ ថ្ងៃ ក្រោយថ្ងៃបោះឆ្នោតសហជីព) និង លក្ខខណ្ឌទី៣ កម្មករនិយោជិតត្រូវជូនដំណឹងដល់និយោជក និងចម្លងទៅក្រសួងទទួលបន្ទុកវិស័យការងារ អំពីឈ្មោះអ្នកដែលត្រូវទទួលការការពារតាមគ្រប់មធ្យោបាយដែលទុកជាបានការ ។"*

កថាខណ្ឌទី០៣ ប្រការ០៣ នៃប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ចែងថា ៖ *" កម្មករនិយោជិតទាំងអស់ដែលជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ទទួលបាននូវការការពារ ចំពោះការបញ្ឈប់ពីការងារដូចប្រតិភូបុគ្គលិកដែរ ។ ការការពារនេះមានរយៈពេល ៤៥ ថ្ងៃ មុនការបោះឆ្នោត ហើយត្រូវបញ្ចប់ក្នុងរយៈពេល ៤៥ ថ្ងៃ ក្រោយការបោះឆ្នោត ប្រសិនបើបេក្ខជនទាំងនេះ មិនត្រូវបានជាប់ឆ្នោត ។ សហជីពត្រូវជូនដំណឹងទៅនិយោជក អំពីបេក្ខភាពនេះតាមគ្រប់មធ្យោបាយទាំងអស់ ដែលទុកជាបានការ ។ និយោជកត្រូវអនុវត្តបទប្បញ្ញត្តិនេះ នៅរាល់ពេលបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព" ។*

នៅក្នុងសេចក្ដីបង្គាប់អាជ្ញាកណ្ដាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានបកស្រាយកថាខណ្ឌទី០៣ ប្រការ០៣ នៃប្រកាសលេខ ៣០៥ ខាងលើថា កម្មករនិយោជិតអាចទទួលបានការការពារពិសេស ដរាបណា (១)កម្មករនិយោជិតជាប្រភេទកម្មករនិយោជិត ដែលទទួលបានការការពារពិសេស (២)ការបញ្ឈប់ត្រូវធ្វើឡើង ក្នុងកំឡុងពេលដែលត្រូវទទួលបានការការពារពិសេស និង (៣) សហជីពត្រូវជូនដំណឹងទៅនិយោជកអំពីបេក្ខភាពកម្មករនិយោ

ជិតដែលត្រូវទទួលការការពារតាមមធ្យោបាយទាំងអស់ ដែលទុកជាបានការ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៥០/០៥-ហ្វូរជ្យូន ហេតុផលនៃចំណុចវិវាទទី១, លេខ ០៧/០៦-ដាយ យ៉ាំង ហេតុផលនៃចំណុចវិវាទទី១, លេខ ១៤៨/០៧-ប៉ាយ ហ៊ី, លេខ ៧១/០៩-ហាយ ថិច ហេតុផលនៃចំណុចវិវាទទី១, លេខ ៣៥/១១-ហ្គោលហ្វៀ ហេតុផលនៃចំណុចវិវាទទី៣, លេខ ១៩១/១២-អា លីម, លេខ ២៤៣/១៣-បឌី ឃីដ ហ្វេសិន វ៉ែរ ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី២, លេខ ០៣៥/១៤-គីន តាយ ហ្គាមិន ខូ.,អិលធីឌី ហេតុផលនៃចំណុចវិវាទទី១, លេខ ៧៤/១៤-ឌី & អិល អាល់ធីមេត ហេតុផលនៃចំណុច វិវាទទី១០, លេខ ០១២/១៥-នីច ធី អ៊ីកែរីល (ខេមបូឌា) ខូ អិលធីឌី ហេតុផលនៃចំណុចវិវាទ និងលេខ ២៧៣/១៥-វិគ្ទូរីយ៉ា អង្គរ ខមភេនី លីមីធីត ហេតុផលនៃចំណុចវិវាទទី១)*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា យោងតាមខ្លឹមសារនៃប្រការ ០៣ នៃប្រកាស ៣០៥ និងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗខាងលើ មិនមានលក្ខណៈផ្ទុយគ្នានឹងខ្លឹមសារនៃមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីពទេ ពីព្រោះដើម្បីទទួលបានការការពារពិសេស កម្មករនិយោជិតត្រូវបំពេញលក្ខខណ្ឌចំនួន ០៣ ដូចការបកស្រាយខាងលើ លើកលែងតែលក្ខខណ្ឌទី៣ ដែលមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីពបានចែងអំពីការចម្លងជូនទៅក្រសួងទទួលបន្ទុកវិស័យការងារ ទាក់ទងនឹងបេក្ខភាពដែលឈរឈ្មោះបោះឆ្នោតសហជីព។ *(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៦៩/១៦-ម៉ានីង តូវី ហ្គាមេន អ៊ិនធើប្រាយ ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី០១)*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងសំណុំរឿងមុនខាងលើដែរ។

ពាក់ព័ន្ធនឹងលក្ខខណ្ឌទី០៣នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការចម្លងជូនដែលមានចែងនៅក្នុងមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីពនេះ មិនគួរចាត់ទុកជាលក្ខខណ្ឌចាំបាច់បន្ថែមសម្រាប់កម្មករនិយោជិតក្នុងការទទួលបានការការពារពិសេសទេ នៅក្នុងករណីដែលនិយោជកបានទទួលលិខិតជូនដំណឹង ឬដឹងពីសមាសភាពរបស់កម្មករនិយោជិតហើយ។ ការចម្លងជូននេះ គឺដើម្បីជាភស្តុតាងបញ្ជាក់បន្ថែមពីសុច្ចរិតភាពរបស់កម្មករនិយោជិត ក្នុងករណីដែលមានការប្រកែក ឬជំទាស់ពីនិយោជកអំពីសមាសភាពរបស់កម្មករនិយោជិតដែលត្រូវទទួលបានការការពារពិសេសនេះ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើកម្មករនិយោជិត គីម លន់ នេះ បានបំពេញគ្រប់លក្ខខណ្ឌទាំង ០៣ ខាងលើនេះ ដែរ ឬទេ?

**លក្ខខណ្ឌទី ០១ ៖ កម្មករនិយោជិតជាប្រភេទកម្មករដែលទទួលបានការការពារពិសេស**

តាមរយៈអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីកម្មករនិយោជិតបានផ្តល់ឯកសារពាក់ព័ន្ធនឹងលិខិតជូនដំណឹងអំពីថ្នាក់ដឹកនាំអាណត្តិទី០១ សហជីពកម្ពុជា ចុះថ្ងៃទី០៧ ខែមិថុនា ដែលបានបោះឆ្នោតនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៦ ដែលក្នុងនោះរួមមាន ៖ កម្មករនិយោជិត សៀក សារ៉េត ជាប់ជាប្រធាន កម្មករនិយោជិត យឹម សុខចា ជាប់ជាអនុប្រធាន និងកម្មករនិយោជិត គីម លន់ ជាប់ជាលេខាធិការិនីសហជីពកម្ពុជា។

យោងតាមមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីពខាងលើ កម្មករនិយោជិត គឹម លន់ ជាប្រភេទកម្មករនិយោជិតដែលទទួលបានការការពារពិសេសពីការបញ្ឈប់ពីការងារ។ ដូចនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ០២ ៖ ការបញ្ឈប់ពីការងារស្ថិតនៅក្នុងពេលដែលកម្មករនិយោជិតបានទទួលនូវការការពារ**

សម្ព័ន្ធសហជីពកម្ពុជា បានរៀបចំបោះឆ្នោតបង្កើតសហជីពកម្ពុជា ប្រចាំក្រុមហ៊ុន ចាយូ នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៦ ហើយនិយោជកបានបញ្ឈប់កម្មករនិយោជិត គឹម លន់ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ការបញ្ឈប់កម្មករនិយោជិត គឹម លន់ គឺបានកើតឡើងបន្ទាប់ពីការបោះឆ្នោតបង្កើតសហជីពកម្ពុជាចំនួន ១៧ថ្ងៃ តែប៉ុណ្ណោះ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ការបញ្ឈប់កម្មករនិយោជិត គឹម លន់ គឺស្ថិតក្នុងអំឡុងពេលដែលទទួលបានការការពារពិសេស។ ដូចនេះ លក្ខខណ្ឌទី២ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ០៣ ៖ កម្មករនិយោជិតបានជូនដំណឹងដល់និយោជក និងចម្លងជូនទៅក្រសួងទទួលបន្ទុកវិស័យការងារ អំពីឈ្មោះកម្មករនិយោជិត ដែលត្រូវទទួលបានការការពារតាមគ្រប់មធ្យោបាយ ដែលទុកជាបានការ**

ភាគីនិយោជកបានលើកឡើងថា និយោជកមិនបានទទួលលិខិតជូនដំណឹងផ្សេងៗអំពីការបង្កើតសហជីពកម្ពុជាទេ។ ដោយឡែក ភាគីកម្មករនិយោជិតបានលើកឡើងថា មន្ត្រីសម្ព័ន្ធសហជីពកម្ពុជាបានជូនដំណឹងពីលទ្ធផលបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពកម្ពុជានៃក្រុមហ៊ុន ចាយូ ដោយយកលិខិតជូនដំណឹងចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ នោះ ទៅក្រុមហ៊ុនផ្ទាល់នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ប៉ុន្តែ សន្តិសុខមិនបានទទួលយកលិខិតនោះទេ។ សម្ព័ន្ធសហជីពកម្ពុជាបានជូនដំណឹងអំពីលទ្ធផលបោះឆ្នោតផងដែរ តាមរយៈប្រៃសណីយ៍នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ ប៉ុន្តែ ប្រៃសណីយ៍បានបញ្ជូនលិខិតនោះមកវិញ ដោយបានបោះត្រាថា និយោជកបដិសេធមិនទទួលនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានរកឃើញមានស្រោមសំបុត្រពីសម្ព័ន្ធសហជីពកម្ពុជាផ្ញើរទៅក្រុមហ៊ុន ចាយូ ខេមបូឌា ដែលមិនទាន់បើក និងបង្កាន់ដៃប្រៃសណីយ៍ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ និងមានបោះត្រា ពីការបដិសេធមិនទទួលយកនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦ ពិតមែន។ ភាគីនិយោជកមិនបានដាក់ឯកសារជំទាស់លើឯកសារនេះទេ។

មាត្រា២៤៦ ស្តីពីការគោលការណ៍នៃការបញ្ជូនដោយឆន្ទានុសិទ្ធិ ជាអាទិ៍ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា ៖ *“៣-ការបញ្ជូនត្រូវបានប្រតិបត្តិដោយបុគ្គលិកប្រៃសណីយ៍ ...”*។

បន្ថែមពីលើនេះ នៅក្នុងសំណុំរឿង លេខ ២៨៣/១៤-ល្បៀន ហ្វា (ខេមបូឌា) ហ្គាមិន ខូ., អិលធីឌី ហេតុផលនៃចំណុចវិវាទទី១០ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ៖ *“ការដែលសហជីពបានជូនដំណឹងតាមប្រៃសណីយ៍ ជាមធ្យោបាយបានការ។ ដោយសារខាងប្រៃសណីយ៍បញ្ជាក់ថា និយោជកមិនទទួលឯកសារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា និយោជកបានដឹងពីការជូនដំណឹងរបស់ភាគីកម្មករនិយោជិតនេះ” (សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៤១/១៦-យី ដា មេឌូហ្វេកធីរី ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី០១ និងទី០២)*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗខាងលើដែរ។

ក្នុងករណីនេះ កម្មករនិយោជិតបានជូនដំណឹងទៅនិយោជកតាមសេវាប្រៃសណីយ៍ ប៉ុន្តែ ខាងសេវាប្រៃស-ណីយ៍បោះត្រាមកវិញថា និយោជកបដិសេធមិនទទួល ហើយភាគីនិយោជកក៏មិនបានដាក់ភស្តុតាងណាមួយជំទាស់នឹងឯកសារពីការផ្ញើតាមប្រៃសណីយ៍នេះដែរ ហេតុនេះយោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតបានជូនដំណឹងដល់និយោជកអំពីឈ្មោះកម្មករនិយោជិត ដែលត្រូវទទួលបានការការពារពិសេសតាមគ្រប់មធ្យោបាយដែលទុកជាបានការហើយ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា និយោជកបានដឹងពីការជូនដំណឹងរបស់កម្មករនិយោជិតនេះដែរ ។

យោងតាមការបកស្រាយ មាត្រា ៦៧ នៃច្បាប់ស្តីពីសហជីព ខាងលើការចម្លងជូនក្រសួងទទួលបន្ទុកវិស័យការងារ មិនគួរជាលក្ខខណ្ឌចាំបាច់បន្ថែមទេ ក្នុងករណីដែលនិយោជកបានដឹង ។ ក្នុងករណីនេះ លក្ខខណ្ឌទី០៣ ត្រូវបានបំពេញ ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិត គឹម លន់ ជាកម្មករនិយោជិតដែលទទួលបានការការពារពិសេសពីការបញ្ឈប់ពីការងារ ។

យោងតាមមាត្រា ៤៣ និងមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីពខាងលើ មុននឹងបញ្ឈប់កម្មករនិយោជិត ដែលត្រូវទទួលបានការការពារពិសេស និយោជកត្រូវស្នើសុំការអនុញ្ញាតជាមុនពីអធិការការងារ ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានអំណះអំណាង អង្គហេតុ ឬភស្តុតាងណាមួយដែលបញ្ជាក់ថា និយោជកបានសុំការអនុញ្ញាតពីអធិការការងារ ក្នុងការកម្មករនិយោជិត គឹម លន់ ពីការងារទេ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការបញ្ឈប់កម្មករនិយោជិតរូបនេះ គឺមិនត្រឹមត្រូវតាមមាត្រា ៤៣ និងមាត្រា ៦៧ នៃ ច្បាប់ស្តីពីសហជីពនោះទេ ។

ប្រការ ៣៤ នៃប្រកាស ០៩៩-ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ២០០៤ ចែងថា ៖ *"...ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសិទ្ធិ និងអំណាចក្នុងការសម្រេចឱ្យភាគីវិវាទផ្តល់នូវសំណងវដ្តប្បវេណី ឬសំណងខូចខាត ដែលមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ ដោយរួមទាំងការ ៖*

*ក. បញ្ជាឱ្យទទួលយកកម្មករនិយោជិត ដែលបានបណ្តេញចេញ ឱ្យចូលមកធ្វើការវិញ នៅតំណែងចាស់ ឬតំណែងសមរម្យណាមួយ*

*ខ. បញ្ជាឱ្យបង់ប្រាក់ជាបន្ទាន់នូវប្រាក់ដែលត្រូវបង់..."* ។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យនិយោជកទទួលយកកម្មករនិយោជិត ដែលទទួលបានការការពារចំពោះការបញ្ឈប់ពីការងារឱ្យចូលធ្វើការវិញ នៅពេលនិយោជកមិនបានសុំការអនុញ្ញាតពីអធិការការងារ ។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៧១/០៩-ហាយផិច អ៊ីស្តស៊ែរ ហេតុផលនៃចំណុចវិវាទទី១, លេខ ០៩/១០-ជុងហាវ, លេខ ៩១/១១-ឃ្វីកស៊ូ ហេតុផលនៃចំណុចវិវាទទី១, លេខ ១៩១/១២-អាលីម (ខេមបូឌា), លេខ ៤៨/១៣-ស៊ុមិ (ខេមបូឌា) វ៉ាយរីង ស៊ីស្ទឹម ហេតុផលនៃចំណុចវិវាទទី១១, លេខ ១៥៦/១៣-ពូយៀន ហេតុផលនៃចំណុចវិវាទទី២, លេខ១៩០/១៣-ឡុងលីដ (ខេមបូឌា), លេខ ៧៤/១៤-ឌី & អិល អាល់ធីមេត ហេតុផលនៃចំណុចវិវាទទី១០, លេខ ១៦៣/១៤-ស៊ីន ឆាង ស៊ីង ហ្គាមេន (ខេមបូឌា), លេខ*

*០១២/១៥-នីច ធី អីកែរីល (ខេមបូឌា) ខូអិលធីឌី ហេតុផលនៃចំណុចវិវាទ និងលេខ ២៧៣/១៥-វីតូរីយ៉ា អង្គរ ខមភេនី លីមីធីត ហេតុផលនៃចំណុចវិវាទទី១)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបង្គាប់ ឱ្យនិយោជកទទួលយកកម្មករនិយោជិត គីម លន់ ឱ្យចូលធ្វើការវិញ និងសងរំលឹកប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗចាប់ពីថ្ងៃបញ្ឈប់ពីការងាររហូតដល់ថ្ងៃចូលធ្វើការវិញ ។

**ចំណុចវិវាទទី ០១ និងទី ០២ (ក្នុងចំណុចបន្ថែមនៅពេលផ្សះផ្សាថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦) ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកកម្មករនិយោជិត សៀក សារ៉េត ឱ្យចូលធ្វើការងារកន្លែងដើមវិញ និងសងរំប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ចាប់ពីថ្ងៃបញ្ឈប់ពីការងាររហូតដល់ថ្ងៃចូលធ្វើការវិញ**

កម្មករនិយោជិត សៀក សារ៉េត បានចាប់ផ្តើមចូលធ្វើការដំបូងនៅក្នុងក្រុមហ៊ុននៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥ ហើយកិច្ចសន្យាការងារចុងក្រោយរបស់គាត់ គឺជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ។ និយោជកបានបញ្ឈប់គាត់ពីការងារនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ បន្ទាប់ពីការប្រជុំផ្សះផ្សានៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ ។ ភាគីកម្មករនិយោជិត បានលើកឡើងថា កម្មករនិយោជិត សៀក សារ៉េត ជាបេក្ខនារីជាប់ជាប្រធាន សហជីពកម្ពុជា ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា ដូចខាងក្រោម ៖

**១. តើកម្មករនិយោជិត សៀក សារ៉េត ទទួលបានការពារពិសេសពីការបញ្ឈប់ពីការងារដែរ ឬទេ?**

ក្នុងករណីនេះ អង្គហេតុពីការបង្កើតសហជីព របស់កម្មករនិយោជិត សៀក សារ៉េត ដូចគ្នានឹងកម្មករនិយោជិត គីម លន់ ដោយហេតុថា យោងតាមការលើកឡើងរបស់ភាគីកម្មករនិយោជិត កម្មករនិយោជិតទាំងពីរជាបេក្ខនារី ដែលជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីពកម្ពុជាដូចគ្នា ដោយកម្មករនិយោជិត សៀក សារ៉េត ជាប់ជាប្រធាន និងកម្មករនិយោជិត គីម លន់ ជាប់ជាលេខាធិការនីសហជីព ។

យោងតាមការបកស្រាយអំពីអង្គច្បាប់ និងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗខាងលើ កម្មករនិយោជិតត្រូវបំពេញលក្ខខណ្ឌចំនួន ០៣ ដើម្បីទទួលបានការការពារពិសេសពីការងារ (*សូមមើលការបកស្រាយលំអិតអំពីលក្ខខណ្ឌក្នុងការទទួលបានការការពារពិសេសក្នុងចំណុចវិវាទទី០១ខាងលើ*) ។

**លក្ខខណ្ឌទី ០១ ៖ កម្មករនិយោជិតជាប្រភេទកម្មករដែលទទួលបានការការពារពិសេស**

យោងតាមការបកស្រាយក្នុងចំណុចវិវាទទី០១ អំពីលក្ខខណ្ឌទី០១ នៃការទទួលបានការការពារពិសេស ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិត សៀក សារ៉េត ជាប្រភេទកម្មករនិយោជិតដែលទទួលបានការការពារពិសេសពីការបញ្ឈប់ពីការងារ ។ ដូចនេះ លក្ខខណ្ឌទី០១ ត្រូវបានបំពេញ ។

THE ARBITRATION COUNCIL

**លក្ខខណ្ឌទី ០២ ៖ ការបញ្ឈប់ពីការងារស្ថិតនៅក្នុងពេលដែលកម្មករនិយោជិតបានទទួលនូវការការពារ**

និយោជកបានបញ្ឈប់កម្មករនិយោជិត សៀក សាវ៉េត នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ការបញ្ឈប់កម្មករនិយោជិត សៀក សាវ៉េត គឺបានកើតឡើងបន្ទាប់ពីការបោះឆ្នោតបង្កើតសហជីពកម្ពុជាចំនួន ២៧ ថ្ងៃ តែប៉ុណ្ណោះ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ការបញ្ឈប់កម្មករនិយោជិត សៀក សាវ៉េត គឺស្ថិតក្នុងអំឡុងពេលដែលទទួលបានការការពារពិសេស។ ដូចនេះ លក្ខខណ្ឌទី០២ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ០៣ ៖ កម្មករនិយោជិតបានជូនដំណឹងដល់និយោជក និងចម្លងជូនទៅក្រសួងទទួលបន្ទុកវិស័យការងារ អំពីឈ្មោះកម្មករនិយោជិត ដែលត្រូវទទួលបានការការពារតាមគ្រប់មធ្យោបាយ ដែលទុកជាបានការ**

យោងតាមការបកស្រាយក្នុងចំណុចវិវាទទី០១ អំពីលក្ខខណ្ឌទី០១ នៃការទទួលបានការការពារពិសេស ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតបានជូនដំណឹងដល់និយោជកអំពីឈ្មោះកម្មករនិយោជិតដែលត្រូវទទួលបានការការពារពិសេស តាមគ្រប់មធ្យោបាយដែលទុកជាបានការហើយ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា និយោជកបានដឹងពីការជូនដំណឹងរបស់កម្មករនិយោជិតនេះដែរ។

បន្ថែមពីលើនេះទៀត ភាគីកម្មករនិយោជិតបានលើកឡើងថា និយោជកបានដឹងពីសមាសភាពរបស់កម្មករនិយោជិត សៀក សាវ៉េត ថា ជាបេក្ខជនជាប់ជាប្រធានសហជីពកម្ពុជា នៅពេលកម្មករនិយោជិតរូបនេះបានចូលរួមផ្សះផ្សានៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ មកម្ល៉េះ ដោយហេតុថា កម្មករនិយោជិតរូបនេះបានចូលរួមផ្សះផ្សា ហើយមន្ត្រីផ្សះផ្សាក៏បានបញ្ជាក់ពីសមាសភាពគាត់ជាប្រធានសហជីពនៅពេលផ្សះផ្សានោះដែរ។

- នៅក្នុងរបាយការណ៍មិនសះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏រកឃើញមានឈ្មោះ កម្មករនិយោជិត សៀក សាវ៉េត ដែលបានចុះតួនាទីជាប្រធានសហជីពកម្ពុជានៅក្រុមហ៊ុន ចាយូ ក្នុងបញ្ជីវត្តមាន កិច្ចប្រជុំស្តីពីដោះស្រាយវិវាទរួមនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកបានដឹងពីសមាសភាពរបស់កម្មករនិយោជិត សៀក សាវ៉េត ថា ជាបេក្ខនារីជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីពហើយ ទោះបីជាភាគីនិយោជកបានជំទាស់នឹងការមិនបានទទួលលិខិតជូនដំណឹងផ្សេងៗអំពីការបង្កើតសហជីពកម្ពុជាក៏ដោយ។

យោងតាមការបកស្រាយ មាត្រា ៦៧ នៃច្បាប់ស្តីពីសហជីព ខាងលើការចម្លងជូនក្រសួងទទួលបន្ទុកវិស័យការងារ មិនគួរជាលក្ខខណ្ឌចាំបាច់បន្ថែមទេ ក្នុងករណីដែលនិយោជកបានដឹង។ ហេតុនេះ លក្ខខណ្ឌទី០៣ ត្រូវបានបំពេញ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិត សៀក សាវ៉េត ជាកម្មករនិយោជិតដែលទទួលបានការការពារពិសេសពីការបញ្ឈប់ពីការងារ។

យោងតាមមាត្រា ៤៣ និងមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីពខាងលើ មុននឹងបញ្ឈប់កម្មករនិយោជិត ដែលត្រូវទទួលបានការការពារពិសេស និយោជកត្រូវស្នើសុំការអនុញ្ញាតជាមុនពីអធិការការងារ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានអំណះអំណាង អង្គហេតុ ឬភស្តុតាងណាមួយ ដែលបញ្ជាក់ថា និយោជកបានសុំការអនុញ្ញាតពីអធិការការងារ ក្នុងការកម្មករនិយោជិត សៀក សារ៉េត ពីការងារទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការបញ្ឈប់កម្មករនិយោជិតរូបនេះ គឺមិនត្រឹមត្រូវតាមមាត្រា ៤៣ និងមាត្រា ៦៧ នៃ ច្បាប់ស្តីពីសហជីពនោះទេ។

ប្រការ ៣៤ នៃប្រកាស ០៩៩ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា ៖ *"...ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសិទ្ធិ និងអំណាចក្នុងការសម្រេចឱ្យភាគីវិវាទផ្តល់នូវសំណងរដ្ឋប្បវេណី ឬសំណងខូចខាត ដែលមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ ដោយរួមទាំងការ ៖*

*ក. បញ្ជាឱ្យទទួលយកកម្មករនិយោជិត ដែលបានបណ្តេញចេញ ឱ្យចូលមកធ្វើការវិញ នៅតំណែងចាស់ ឬតំណែងសមរម្យណាមួយ*

*ខ. បញ្ជាឱ្យបង់ប្រាក់ជាបន្ទាន់នូវប្រាក់ដែលត្រូវបង់..."* ។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យនិយោជកទទួលយកកម្មករនិយោជិត ដែលទទួលបានការការពារចំពោះការបញ្ឈប់ពីការងារឱ្យចូលធ្វើការវិញ នៅពេលនិយោជកមិនបានសុំការអនុញ្ញាតពីអធិការការងារ។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៧១/០៩-ហាយចិច អឹមកែរីល ហេតុផលនៃចំណុចវិវាទទី១, លេខ ០៩/១០-ជុងហាវ, លេខ ៩១/១១-ឃ្វីកស៊ូ ហេតុផលនៃចំណុចវិវាទទី១, លេខ ១៩១/១២-អាលីម (ខេមបូឌា), លេខ ៤៨/១៣-ស៊ុមិ (ខេមបូឌា) ក៉ាយរឹង ស៊ីស្វឹម ហេតុផលនៃចំណុចវិវាទទី១១, លេខ ១៥៦/១៣-ពូយឿន ហេតុផលនៃចំណុចវិវាទទី២, លេខ១៩០/១៣-ឡុងលីដ (ខេមបូឌា), លេខ ៧៤/១៤-ឌី & អិល អាល់ធីមេត ហេតុផលនៃចំណុចវិវាទទី១០, លេខ ១៦៣/១៤-ស៊ីន ឆាង ស៊ីង ហ្គាមេន (ខេមបូឌា), លេខ ០១២/១៥-ទីច ធី អឹកែរីល (ខេមបូឌា) ខូអិលធីឌី ហេតុផលនៃចំណុចវិវាទ និងលេខ ២៧៣/១៥-វីតូរីយ៉ា អង្គរ ខមភេនី លីមីធីត ហេតុផលនៃចំណុចវិវាទទី១*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបង្គាប់ ឱ្យនិយោជកទទួលយកកម្មករនិយោជិត សៀក សារ៉េត ឱ្យចូលធ្វើការវិញ និងសងរំលឹកប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ចាប់ពីថ្ងៃបញ្ឈប់ពីការងាររហូតដល់ថ្ងៃចូលធ្វើការវិញ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

**សម្រេច និង បង្គាប់**

**ចំណុចវិវាទទី ០១ ៖**

- បង្គាប់ឱ្យនិយោជកទទួលយកកម្មករនិយោជិត គឹម លន់ ឱ្យចូលធ្វើការវិញ ។

ចំណុចវិវាទទី ០១ និងទី ០២ (ក្នុងចំណុចបន្ថែមនៅពេលផ្សះផ្សាថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦) ៖

- បង្គាប់ឱ្យនិយោជកទទួលយកកម្មករនិយោជិត សៀក សារ៉េត ឱ្យចូលធ្វើការវិញ និងសងរំលឹកប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ចាប់ពីថ្ងៃបញ្ឈប់ពីការងារ រហូតដល់ថ្ងៃចូលធ្វើការវិញ ។

ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍ អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ ។*

ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **សេខ ទួចហ៊ុន**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា ៖------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ិនឈា**

ហត្ថលេខា ៖ ------------------------------

ARBITRATION COUNCIL